ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៦៨
ចុះថ្ងៃទី០៧-០៩-២០០១
សាលដីកាលេខ៖ ៤៧
ចុះថ្ងៃទី០៣-១២-២០០៣

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៣ខែធ្នូឆ្នាំ ២០០៣ ដោយមាន សមាសភាពក្រុម ប្រឹក្សាជំនុំជម្រះដូចតទៅ៖

១-ឯកឧត្តម … ប្រធាន
២-លោក … ចៅក្រម
៣-លោក … ចៅក្រម
៤-លោក … ចៅក្រមរបាយការណ៍
៥-លោក … ចៅក្រម

ក្រឡាបញ្ជី
លោក…
តំណាងមហាអយ្យការ
លោក…ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះ បណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ២៤០ចុះ ថ្ងៃទី ១៨-១០-00 របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៦៨ ចុះថ្ងៃទី ០៧-៩-០១ របស់តុលាការកំពូល។

ពីបទៈប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនាមានអារ៉ុធ ប្រព្រឹត្តនៅភូមិស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៣-០៤-១៩៩៧ តាមបញ្ញត្តិមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

- ជនជាប់ចោទឈ្មោះ **សហ** (ចុងបណ្តឹងសាទុក្ខ) ភេទប្រុសអាយុ២៥ឆ្នាំ ជាតិខ្មែរ រមុខរបរធ្វើស្រែទីកន្លែងកំណើត និងទីលំនៅភូមិកំពង់ឈើទាល ឃុំតោងក្រសៅ ស្រុកសន្ទុក ខេត្តកំពង់ធំ។ ឪពុកឈ្មោះ **សស** ម្តាយឈ្មោះ **សអ**។ នៅលីវ។នៅក្រៅឃុំ។

-មេធាវី គ្មាន

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ងឃ** "ម្ចាស់បណ្តឹងសាទុក្ខ" ភេទ ប្រុសអាយុ៤៨ឆ្នាំជាតិខ្មែរ មានទីលំនៅភូមិអន្លង់ក្រសាំង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ឪពុកឈ្មោះ...ម្តាយឈ្មោះ...ប្រពន្ធឈ្មោះ... មានកូន០៣ នាក់។

- មេធាវី លោក...

- តាមពាក្យបណ្តឹងចុះថ្ងៃទី១៣-៤-១៩៩៧ របស់ឈ្មោះ **ងឃ** ថាៈ នៅថ្ងៃទី១៣-៤-៩៧ ម៉ោង៧ព្រឹកត្រូវថ្ងៃបុណ្យចូលឆ្នាំខ្មែរ ខ្លួនបានជិះកង់មកពីភូមិឈើទាល ទៅភូមិស្វាយពេលមកដល់ភូមិស្រើង ក្បែររោងម៉ាស៊ីនស្រូវឈ្មោះ **សអ** ពេលនោះឈ្មោះ **សអ** បានស្រែកហៅខ្លួនឱ្យឈប់ ហើយគាត់បានសួរខ្លួនថាម្តេចបានជាឯងទៅនិយាយដល់អ្នកភូមិស្វាយថា ម៉ាស៊ីនអញស៊ីអង្ករច្រើន រួចខ្លួនឆ្លើយតបថា ខ្លួនមិនបាននិយាយដូច្នេះទេ ហើយរំពេចនោះក៏ស្រាប់តែឈ្មោះ **សហ** ជាកូនគាត់បានរត់ពីរោងម៉ាស៊ីនមកដោយកាន់កាំបិតកុកមកផង មកដល់បម្រុងកាប់ក្បាលខ្លួន តែពេលនោះខ្លួនឃើញទាន់ បានយកដៃឆ្វេងរងកាំបិតបណ្តាលឱ្យមុតកំភួនដៃដល់ឆ្អឹង។ រួចវាបម្រុងកាប់ខ្លួនទៀត ខ្លួនរត់គេចទាន់ក្នុងរឿងនេះខ្លួនសុំប្តឹងទាមទារជំងឺចិត្ត១០លានរៀលនិងសុំផ្តន្ទាទោស តាមច្បាប់។

- បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការអមតុលាការខេត្ត កំពង់ធំថា:ចោទប្រកាន់លើឈ្មោះ **សហ** ភេទប្រុសអាយុ២៥ឆ្នាំ ជាតិខ្មែរ កើត និងសព្វថ្ងៃ នៅភូមិកំពង់ឈើទាល ឃុំតាំង ក្រសៅ ស្រុកសន្ទុក ខេត្ត កំពង់ធំ កម្រិតវប្បធម៌ថ្នាក់ទី៥ មុខរបរធ្វើស្រែ **<u>ពីបទ:</u>** ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្ត នៅភូមិស្រ៊ើង ឃុំស្រ៊ើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៣-៤-១៩៩៧ តាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១៣៦ ចុះថ្ងៃទី៣១-១២-១៩៩៧ របស់តុលាការខេត្តកំពង់ធំ ដែលមានសេចក្តីសម្រេចដូចតទៅ៖

-ផ្តន្ទាទោសឈ្មោះ **សហ** ដាក់ពន្ធនាគារចំនួន២ ឆ្នាំតែទោសនេះត្រូវព្យួរ តាមមាត្រា៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ពីបទបង្ករបួសស្នាមដោយចេតនាមានអាវុធ កាលពីថ្ងៃទី១៣-៤-១៩៩៧ នៅភូមិស្រើង ឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ បទល្មើសព្រហ្មទណ្ឌ ដែលបានចែងនិងផ្តន្ទាទោសតាមមាត្រា៤១ និង៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ទោសខាងលើនេះ គិតតាំងពីថ្ងៃសាលក្រមមាន អានុភាពតទៅ។

២ - វត្ថុតាងមានកាំបិតកុកមានចំនួន១ ត្រូវរឹបអូសនិងបំផ្លាញចោល។

៣ - ឱ្យឈ្មោះ **សហ** ជួសជុលសំណង និងជំងឺចិត្តជាប្រាក់៣លានរៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ងឃ**។ បណ្តឹងលើសពីនេះត្រូវ លើកចោល បើឈ្មោះ **សហ** មិនមានលុយសងទេ ត្រូវដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ

៤ -សាលក្រមនេះ ប្រកាសាធារណ:ចំពោះមុខគូភាគី បើភាគីណាមិនសុខចិត្ត មានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

- ឃើញបណ្តឹងឧទ្ធរណ៍លេខ០១ ចុះថ្ងៃទី០៨-០១-៩៨ របស់ឈ្មោះ **សហ** ដែលប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ១៣៦ ចុះថ្ងៃទី៣១-១២-១៩៩៧ របស់តុលាការខេត្តកំពង់ធំ ត្រង់ចំណុចទី៣ នៃសេចក្តីសម្រេច។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ០២ ចុះថ្ងៃទី១៣-០១-១៩៩៨ របស់ឈ្មោះ **ងឃ** ដែលប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ១៣៦ ចុះថ្ងៃទី៣១-១២-៩៧ របស់តុលាការខេត្តកំពង់ធំ លើសេចក្តីសម្រេចទាំងមូល។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ០១ ចុះថ្ងៃទី០៨-០១-៩៨ របស់ជនជាប់ចោទឈ្មោះ **សហ** ទុកជាត្រឹមត្រូវ តាមទម្រង់តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-ទទួលបណ្តឹងឧទ្ធរណ៍លេខ០២ ចុះថ្ងៃទី១៣-០១-៩៨ របស់ដើមបណ្តឹង **ងឃ** ទុកជាត្រឹមត្រូវ តាមទម្រង់និងគតិច្បាប់។

៣-បដិសេធចោលសាលក្រមលេខ១៣៦ចុះថ្ងៃទី៣១-១២-៩៧ របស់តុលាការខេត្តកំពង់ធំ ជាអសារបង់។

៤-ជំនុំជម្រះឡើងវិញ ក្នុងបទចោទប្រកាន់ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ២៤០ ចុះថ្ងៃទី១៨-១០-២០០០ របស់សាលាឧទ្ធរណ៍ នៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ០១ ចុះថ្ងៃទី០៨-០១-៩៨ របស់ឈ្មោះ **សហ** ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ០២ ចុះថ្ងៃទី១៣-០១-៩៩ របស់ឈ្មោះ **ងយ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

៣-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ១៣៦ ចុះថ្ងៃទី៣១-១៦-១៩៩៧របស់តុលាការខេត្តកំពង់ធំចោលជាអសារបង់ដោយសំអាងជាថ្មីថា៖

ក-កែប្រែបទល្មើសពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា មកជាបង្ករបួសស្នាមដោយចេតនាមានអាវុធប្រព្រឹត្តនៅឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៣-០៤-៩៧ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលវិញ។

ខ-សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារឈ្មោះ **សហ** កំណត់ពីរឆ្នាំ ដោយឱ្យជាប់ពន្ធនាគារ ០៣ខែ គិតចាប់ពីថ្ងៃទី២៩-០៩-៩៧ ដល់ថ្ងៃទី៣១-១២-៩៧ ទោសនេះបានទទួលរួចហើយ សល់ពីនេះត្រូវព្យួរក្នុងការសាកល្បង០៥ឆ្នាំ គិតពីថ្ងៃដីកាចូលស្ថាពរ ពីបទបង្ករបួសស្នាមដោយចេតនាមានអាវុធប្រព្រឹត្តនៅឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៣-០៤-៩៧ តាមបញ្ញត្តិមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

គ-សម្រេចឱ្យឈ្មោះ **សហ** ចេញសោហ៊ុយខាតបង់ជំងឺចិត្តជាប្រាក់ចំនួន ៦០០.០០០រៀល (ហុកសិបម៉ឺនរៀល) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ងយ សំណូមពរលើសពីនេះបដិសេធចោល ក្នុងករណីឈ្មោះ **សហ** គ្មានប្រាក់សងឱ្យឈ្មោះ **ងយ** ទេត្រូវដាក់គុកបង្ខំរូបកាយតាមមាត្រា៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ដើម្បីទារប្រាក់ធនទណ្ឌ។

៤-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងសាទុក្ខក្នុងរយៈពេលពីរខែចាប់ពីថ្ងៃនេះតទៅ។

-បានឃើញបណ្ដឹងសាទុក្ខលេខ១០៨ចុះថ្ងៃទី១៣-១២-២០០០ របស់ឈ្មោះ **ងយ** ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ២៤០ ចុះថ្ងៃទី១៨-១០-២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសម្រេចទាំងមូល។

-បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖

មានពិរុទ្ធភាពគ្រាប់គ្រាន់លើឈ្មោះ **សហ** ពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនាប្រព្រឹត្តនៅភូមិស្រ៊ីង ឃុំស្រ៊ីង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំកាលពីថ្ងៃទី១៣-៤-៩៧ បទល្មើសដែលត្រូវផ្ដន្ទាទោសតាមមាត្រា៤១ និង៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។ សូមបដិសេធសាលដីកាព្រហ្មទណ្ឌលេខ២៤០ ចុះថ្ងៃទី១៨-១០-២០០០ របស់សាលាឧទ្ធរណ៍ចោលជាអសាបង់។

-បានស្ដាប់សាវតាជាតិ និងចម្លើយរបស់ឈ្មោះ **ងយ** ជាដើមបណ្ដឹងរដ្ឋប្បវេណីនាពេលសវនាការថា៖ ហេតុដែលខ្ញុំបាទប្ដឹងឡើងមកកំពូលនេះ ដោយសារសាលាឧទ្ធរណ៍សម្រេចកាត់បន្ថយសំណងជំងឺចិត្តនិងឱ្យជនល្មើសរួចខ្លួន។

-ជនល្មើសឈ្មោះ **សហ** អ្នកកាប់សំដៅឱ្យចំក្បាលខ្ញុំ ហើយខ្ញុំក៏យកដៃរងបណ្ដាលឱ្យដាច់បាក់ឆ្អឹង។

-ចំពោះម្ដាយជនល្មើសអ្នកចាប់ដៃឱ្យកូនកាប់ សូមតុលាការកំពូលមេត្តារកយុត្តិធម៌ដល់ខ្ញុំបាទជាអ្នករងគ្រោះផង។

-បានស្ដាប់ក្រឡាបញ្ជីអានសាវតាជាតិជនជាប់ចោទឈ្មោះ **សហ**

-បានស្ដាប់មេធាវីលោក... បានធ្វើសេចក្ដីសន្និដ្ឋាននាពេលសវនាការថា ៖ អំពើល្មើសរបស់ឈ្មោះ **សហ** ពិតជាប៉ុនប៉ងធ្វើមនុស្សឃាតលើកូនក្ដីរបស់ខ្ញុំពិតប្រាកដ ដោយចេតនាកាប់នឹងកាំបិតផ្គាក់។

-តុលាការខេត្តកំពង់ធំ សម្រេចចោទប្រកាន់ជនល្មើលពីបទប៉ុនប៉ងធ្វើមនុស្សឃាត

-សាលាឧទ្ធរណ៍កែប្រែបទល្មើស និងសំណង ដោយបដិសេធសាលក្រមតុលាការខេត្ត ការសម្រេចបែបនេះ មិនសមស្របការរងគ្រោះរបស់កូនក្តីខ្ញុំឡើយ ហើយក៏ពុំត្រឹមត្រូវតាមច្បាប់ដែរ សូមក្រុមប្រឹក្សាតុលាការកំពូលសម្រេចសេចក្តីរកយុត្តិធម៌ឡើងវិញ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា ពុំមានអ្វីបន្ថែមទៀតទេ សូមរក្សាការសន្និដ្ឋានរបស់ខ្លួនទុកជាបានការដដែល។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមបណ្តឹរដ្ឋប្បវេណី

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថាបណ្តឹងសាទុក្ខលេខ១០៨ ចុះថ្ងៃទី ១៣-១២-២០០០ របស់លោក **ងយ** ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី។

យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ សម្រេចបន្ថយសោហ៊ុយខាតបង់ និងជំងឺចិត្តពី ៣.០០០.០០០រៀលមក ៦០០.០០០រៀល ដែលជនជាប់ចោទត្រូវបង់ឱ្យដើមបណ្តឹងនោះ គឺជាការភាន់ច្រឡំ ពីព្រោះថាសាលាឧទ្ធរណ៍

បានសម្រេចបដិសេធពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៩៨ របស់ជនជាប់ចោទឈ្មោះ **សហ** ដោយទាស់នឹងគតិច្បាប់ ប៉ុន្តែបែរជាសម្រេចផ្តល់ផលប្រយោជន៍ឱ្យជាប់ចោទទៅវិញ។

យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ និងតុលាការខេត្ត កំពង់ធំសម្រេចកែប្រែបទចោទ ពីបទប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា មកជាបទបង្ករបួសស្នាមដោយចេតនាមានអាវុធ ហើយផ្តន្ទាទោសជនជាប់ចោទ ពីបទបង្ករបួសស្នាមដោយចេតនា នេះគឺជាការភាន់ច្រឡំ ពីព្រោះថា តាមអង្គហេតុនៃរឿងនេះបង្ហាញឱ្យថា ជនជាប់ចោទបានត្រៀមលក្ខណៈទុកជាមុន ហើយមានទាំងអាវុធផង ដែលអាវុធនេះ ពិតជាមធ្យោបាយអាចធ្វើមនុស្សឃាតបាន។ ម្យ៉ាងទៀតជនជាប់ចោទ បានកាន់កាំបិតសំដៅជនរងគ្រោះរួចកាប់មួយទំហឹងពេញកម្លាំង។កាប់សំដៅចំក្បាល ជាកន្លែងដែលងាយនឹងរងគ្រោះបណ្តាលឱ្យស្លាប់បាន រួចហើយដេញតាមថែមទៀតពេលដែលជនរងគ្រោះរត់គេចពីគ្រោះថ្នាក់។

-ឃើញថា ការដែលមេធាវីជនរងគ្រោះ សុំឱ្យតុលាការកំពូល ចោទប្រកាន់ម្តាយជនជាប់ចោទនោះ តុលាការកំពូល ពុំមានសមត្ថកិច្ចចោទប្រកាន់ទេ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិប្តឹងសុំទៅព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ធំ ដើម្បីធ្វើការចោទប្រកាន់បាន។

-យល់ឃើញថា ជនជាប់ចោទពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវី មកចូលរួម ដូច្នេះតុលាការកំពូល ជំនុំជម្រះកំបាំងមុខ ចាត់ទុកជាចំពោះមុខ។

-ឃើញថាសាលដីកាព្រហ្មទណ្ឌលេខ២៤០ ចុះថ្ងៃទី១៨-១០-២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមក នេះមានការខុសឆ្គងទាំងទម្រង់ទាំងគតិច្បាប់។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខ ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ១០៨ ចុះថ្ងៃទី១៣-១២-២០០០ របស់លោក **ងយ** ទុកជាត្រឹមត្រូវ តាមទម្រង់ នឹងគតិច្បាប់។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ២៤០ចុះថ្ងៃទី១៨-១០-០០ របស់សាលាឧទ្ធរណ៍ទាំងមូល។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៦៨ ចុះថ្ងៃទី០៧-៩-២០០១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជម្រះឡើងវិញ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ ២០០៣។